# រៀនតែងកំណាព្យខ្មែរ

(ស្រង់ពីសៀវភៅ រៀនតែងកំណាព្យខ្មែរ (១៥ថ្ងៃ...ក្លាយជាកវី)
របស់ក្រុមអ្នកនិពន្ធ ស្លាបប៉ាកកាមាស ឆ្នាំ២០១០

## -អត្ថន័យវាក្យសព្ទ

អត្ថន័យនៃបញ្ញត្តិ «កាព្យ, កំណាព្យ, ពាក្យចួន»

**កាព្យ** (ន.) របៀបពាក្យចួនមានឃ្លោងឃ្លា(កំណាព្យ)ៈពាក្យកាព្យ, តែងកាព្យ។ **កាព្យ** - សិល្បអត្ថបទដែលជាពាក្យចួន

**កំណាព្យ** (ន.) ពាក្យកាព្យៈ លើកកំណាព្យ, តែងកំណាព្យ។ **កំណាព្យ** - សិល្បៈតែងកាព្យសិល្បៈអន្ទង និងបំផុសមនោសញ្ចេតនា ចំណាប់អារម្មណ៍ ការរំភើបញាប់ញ័រ ដោយការគួបផ្សំ វណ្ណសូរសំឡេង ចង្វាក់ និងភាពពីរោះ។

**ពាក្យចួន** - កម្រងពាក្យដែលប្រកបដោយចង្វាក់វណ្ណ សូរសំឡេង ពាក្យពីរោះណែងណង។

ដូចនេះ **អត្ថន័យកំណាព្យ** គឺស្ថិតនៅលើការអប់រំ បណ្តុះសតិអារម្មណ៍ល្អៗដល់អ្នកអាន អ្នកស្តាប់ តាមរយៈសំនួនវោហារ និងសិល្បវិធី ដើម្បីបំពេអ្នកអាន អ្នកស្តាប់ ទៅដល់ការខិតខំហាត់ពត់លត់ដំចំណង់តណ្ហា ហើយអប់រំកែប្រែចំណង់តណ្ហាទាំងនោះបានល្អប្រសើរ ដើម្បីស្វែងរកសន្តិភាព សេរីភាព ឯករាជ្យ សុភមង្គល ជូនសង្គម និងមនុស្សជាតិ។

## -ប្រភពកំណាព្យខ្មែរ

កំណាព្យខ្មែរ មានកំណើតដំណាលគ្នាទៅនឹងការកើតឡើងនៃចង្វាក់ផលិតកម្ម (មានពលកម្ម មានអក្សរសិល្ប៍ មានកំណាព្យ មានចម្រៀង)។ ឆន្ទ(បាលីហៅកាព្យឬកំណាព្យថាឆន្ទ)សំស្រ្កឹត បានជួយតម្រង់បែប និងទម្រង់របស់កំណាព្យខ្មែរប្រែជាមានក្បួនខ្នាតត្រឹមត្រូវចាប់ពីមុនសម័យអង្គរ ហើយបន្តមកដល់សម័យអង្គរ និងសម័យក្រោយអង្គរ។ គេប្រទះឃើញកំណាព្យសរសេរជាភាសាសំស្រ្កឹតយ៉ាងល្អឥតខ្ចោះ នៅតាមផ្ទាំងសិលាចារឹកខ្មែរ(សម័យមុនអង្គរ និងសម័យអង្គរ) ឯកំណាព្យជាភាសា(វាកសព្ទ)ខ្មែរដំបូង ត្រូវបានគេប្រទះឃើញនៅឯ **សិលាចារឹកជ័យនន្ទ** ក្នុងគ.ស ១៧០១។

## -ធាតុសំខាន់ៗរបស់កាព្យ (កំណាព្យ)

កំណាព្យ(សិល្បៈតែងកាព្យ)ក៏ដូចជាមុខវិជ្ជាដទៃទៀត ដែរតែងតែមានធាតុសំខាន់ៗដើម្បីទ្រទ្រង់ និងសម្គាល់អត្តសញ្ញាណរបស់ខ្លួនផ្ទាល់។ ធាតុសំខាន់ៗរបស់កំណាព្យមាន៖ រង្វាស់កាព្យ ចំណាប់ចុងចួន និងបរិយាកាស។

- **រង្វាស់កាព្យ**(កាព្យមាត្រ)គឺចំនួនព្យាង្គក្នុងឃ្លានីមួយៗ និងចំនួនឃ្លាក្នុងវគ្គនីមួយៗ។
- **ចំណាប់ចុងចួន**(រូបសម្ផស្ស)ជាព្យាង្គដែលត្រូវចួនគ្នា។ ចំណាប់ចុងចួនមានពីរបែបគឺ ចួនក្នុងវគ្គ(រូបសម្ផស្សក្នុង) និងចួនឆ្លងវគ្គ(រូបសម្ផស្សក្រៅ)។ ការចាប់ចុងចួន ត្រូវគោរពតាមក្បួនកាព្យនីមួយៗយ៉ាងតឹងរឹង ប្រកបដោយអត្តរូប អត្ថន័យ និងអត្ថរស។
- **បរិយាកាស** គឺជាពេលវេលា ឬឱកាសដែលគេយកបទនោះទៅប្រើប្រាស់។
- **ចង្វាក់** គឺបែបបទក្នុងការសូត្រកំណាព្យ ត្រូវទម្លាក់សំឡេងលើព្យាង្គក្នុងឃ្លានៃវគ្គនីមួយៗ។

# ក្បួនតែងកាព្យខ្មែរ

## ១- បទ ពាក្យ៤ ឬ បទមេ៤ ឬ បទ៤ព្យាង្គ

* បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ) បទនេះច្រើនយកទៅប្រើក្នុងការបង្ហាញពីសភាពនៃពលកម្ម ឬការងារ។
* គំនូសតាងបទកាព្យ

- ①②③④ ①②③④ ①②③④ ①②③④ ។

- ①②③④ ①②③④ ①②③④ ①②③④ ។

*វង្វាស់កាព្យ(កាព្យមាត្រ)

-១វគ្គ(ល្បះ)មាន៤ឃ្លា ហើយឃ្លានីមួយៗមាន៤ព្យាង្គ។

*ចំណាប់ចុងចួន(រូបសម្ពស្ស)

- ចួនក្នុងវគ្គ(រូបសម្ពស្សក្នុង)

ព្យាង្គទី៤នៃឃ្លាទី២ ចួននឹងព្យាង្គទី៤នៃឃ្លាទី៣។

-ចួនឆ្លងវគ្គ(រូបសម្ពស្សក្រៅ)

ព្យាង្គទី៤នៃឃ្លាទី៤ក្នុងវគ្គទី១(វគ្គមុន) ចួននឹងព្យាង្គទី៤នៃឃ្លាទី២ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖

បើនាងបុកស្រូវ កុំចោល**អង្កាម** ចាស់ទុំលោក**ហាម** អង្កាមជាន់**ឥដ្ឋ** ។
អង្ករសម្រួប ទៅជា**សម្រិត** សម្រាំងពីចិត្រ ដោយសារដៃនាង ។ (កំណាព្យបុរាណ)

## ២- បទ បន្ទោលវគ្គ

* បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ) បទនេះច្រើនយកទៅប្រើក្នុងឱកាសពិធីបុណ្យសាសនា(ព្រះពុទ្ធ) ដើម្បីអប់រំ ទូន្មាន ការជាស់តឿន ក្រើនរំលឹក ឬជួនកាលគេយកទៅប្រើក្នុងការសម្តែងទុក្ខសោកផងដែរ។
* គំនូសតាងបទកាព្យ

- ①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧
①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧ ។

- ①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧
①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧ ។

*វង្វាស់កាព្យ(កាព្យមាត្រ)

-១វគ្គ(ល្បះ)មាន៤ឃ្លា ហើយឃ្លានីមួយៗមាន៨ព្យាង្គ។

*ចំណាប់ចុងចួន(រូបសម្ពស្ស)

- ចួនក្នុងវគ្គ(រូបសម្ពស្សក្នុង)

ព្យាង្គទី ៨នៃ ឃ្លាទី១ ចួននឹង ព្យាង្គទី៤ នៃឃ្លាទី២។
និង ព្យាង្គទី៨ នៃឃ្លាទី២ ចួននឹង ព្យាង្គទី៨ នៃឃ្លាទី៣។

-ចួនឆ្លងវគ្គ(រូបសម្ពស្សក្រៅ)

ព្យាង្គទី៨ នៃឃ្លាទី៤ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី៨ នៃឃ្លាទី២ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖
-ធម៌សុខទីមួយមេត្តាគ្រប់ទី សព្វសត្វជីវី កុំប៉ងពាធា
ប្រមាណសម្លាប់ផ្ដិលផ្ដាច់ជន្មា ត្រូវមានសទ្ធាការពារជីវិត ។
-ធម៌សុខទីពីរកុំប៉ុនប៉ងគិត លង់ក្នុងគំនិតគិតគន់គ្នាន់គ្នេរ
កេងកិបប្រវ័ញ្ចលួចសម្បត្តិគេ គួរកុំវៀចវេរលោភលន់ចង់បាន។ (សមាគមវញ្ញូនពុទ្ធិបពោធនមិត្ត)

## ៣-បទកាកគតិ (កាកៈ ក្អែក + គតិៈ ដំណើរ = ដំណើរក្អែក)

* **បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បទនេះច្រើនយកទៅប្រើក្នុងការពិពណ៌នា(តួអង្គ ទីកន្លែង ធម្មជាតិ...) ពិធីផ្ដើមរឿង ហើយជួនកាលកវីខ្លះយកបទនេះទៅប្រើក្នុងការសម្ដែងទុក្ខសោក ឬអប់រំផងដែរ។

* **គំនូសតាងបទកាព្យ**

- ①②③④ ①②③④ ①②③④
①②③④ ①②③④ ①②③④
①②③④ ។

- ①②③④ ①②③④ ①②③④
①②③④ ①②③④ ①②③④
①②③④ ។

***រង្វាស់កាព្យ(កាព្យមាត្រ)**

-១វគ្គ(ល្បះ)មាន៧ឃ្លា ហើយឃ្លានីមួយៗមាន៤ព្យាង្គ។

***ចំណាប់ចុងចួន(រូបសម្ផស្ស)**

- ចួនក្នុងវគ្គ(រូបសម្ផស្សក្នុង)

ព្យាង្គទី៤ នៃឃ្លាទី១ ចួននឹង ព្យាង្គទី៤ នៃឃ្លាទី២។
និង ព្យាង្គទី៤ នៃឃ្លាទី៣ ចួននឹង ព្យាង្គទី៤ នៃឃ្លាទី៥ ចួននឹងព្យាង្គទី៤ នៃឃ្លាទី៦ ។
ព្យាង្គទី៤ នៃឃ្លាទី៤ ចួននឹងព្យាង្គទី២ នៃឃ្លាទី៥(កវីខ្លះពុំបានអនុវត្តចំណាប់ចួននេះទេ)

-ចួនឆ្លងវគ្គ(រូបសម្ផស្សក្រៅ)

ព្យាង្គទី៤ នៃឃ្លាទី៧ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី៤ នៃឃ្លាទី៣ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖

- កុំស្អប់អ្នកតូច បើឃើញគ្នាខូច គួរគិតប្រមុម
ទោសគ្នាតិចតូច ផ្ដើមផ្ដួចជាធំ ផ្សែងពូតជាដុំ
ផ្លុំឆេះជាភ្លើង ។

- កុំភ្លើនភ្លេចខ្លួន បេះសាសន៍ចិន-យួន កុំភ្លេចខ្មែរយើង
កុំធ្វើក្រអឺត កុំពើតកំពើង កុំពាក់ស្បែងជើង
ចូលវត្តលោកសង្ឃ ។ (ក្រមង៉ុយ)

## ៤- បទព្រហ្មគីតិ (ព្រហ្មៈ ព្រះព្រហ្ម + គីតិៈ ទំនួញ, ចម្រៀង = ទំនួញ ឬចម្រៀងរបស់ព្រះព្រហ្ម)

*** បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បទនេះ ច្រើនយកទៅប្រើក្នុងការសម្ដែង ទុក្ខសោក ភាពលន្លង់លន្លោច ការព្រាត់ប្រាសគ្នា អប់រំ ទូន្មាន ប្រៀនប្រដៅ ឬការឈឺចាប់ពីអំពើជិះជាន់ផងដែរ។

*** គំនូសតាងបទកាព្យ**

- ①②③④⑤ ①②③④⑥⑥ → ①②③④⑤⑥

①②③④⑤ ①②③④⑤⑥ ។

- ①②③④⑤ ①②③④⑤⑥

①②③④⑤ ①②③④⑤⑥ ។

***រង្វាស់កាព្យ(កាព្យមាត្រ)**

-១វគ្គ(ល្បះ)មាន៤ឃ្លា ឃ្លាទី១,ទី៣ មាន៥ព្យាង្គ និងឃ្លាទី២,ទី៤ មាន៦ព្យាង្គ។

***ចំណាប់ចុងចួន(រូបសម្ពស្ស)**

- ចួនក្នុងវគ្គ(រូបសម្ពស្សក្នុង)

ព្យាង្គទី៥ នៃឃ្លាទី១ ចួននឹង ព្យាង្គទី៣ នៃឃ្លាទី២។

ព្យាង្គទី៦ នៃឃ្លាទី២ ចួននឹងព្យាង្គទី៥ នៃឃ្លាទី៣ ចួននឹងព្យាង្គទី៣ នៃឃ្លាទី៤។

(...ចួននឹងព្យាង្គទី៣ នៃឃ្លាទី៤ កវីខ្លះពុំបានអនុវត្តចំណាប់ចួននេះទេ)

-ចួនឆ្លងវគ្គ(រូបសម្ពស្សក្រៅ)

ព្យាង្គទី៦ នៃឃ្លាទី៤ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី៦ នៃឃ្លាទី២ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖

- ពីថ្ងៃនេះទៅមុខ ត្រូវចាំទុកពាក្យពុកផ្ដាំ
រកស៊ីតាមចំណាំ ជីវកម្មដែលសុចរិត ។
- កុំពោលពាក្យមុសា ថ្លែងវាចាតាមក្រមក្រឹត្យ
ទើបមានគេស្នេហ៍ស្និទ្ធ ស្មោះជាប់ចិត្តជុំវិញប្រាណ ។ (វ៉ែន សុន)

## ៥- បទបន្ទោលកាក (មណ្ឌុក(កង្កែប) + គតិ = ដំណើរកង្កែប )

*** បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បទនេះ បុរាណច្រើនយកទៅប្រើក្នុងការពោលរៀបរាប់ ពីដំណើររឿងនៃល្បើកកថា សកម្មភាពតួអង្គ សម្ដែងទុក្ខសោក ភាពលន្លង់លន្លោច ការព្រាត់ប្រាសគ្នា ការអប់រំ ទូន្មាន ប្រៀនប្រដៅផងដែរ។

*** គំនូសតាងបទកាព្យ**

①②③④ ①②③④⑤⑥

①②③④ ①②③④⑤⑥ ។

①②③④ ①②③④⑤⑥

①②③④ ①②③④⑤⑥ ។

***រង្វាស់កាព្យ(កាព្យមាត្រ)**

-១វគ្គ(ល្បះ)មាន៤ឃ្លា ឃ្លាទី១,ទី៣ មាន៤ព្យាង្គ និងឃ្លាទី២,ទី៤ មាន៦ព្យាង្គ។

*ចំណាប់ចុងចួន(រូបសម្ពស្ស)

- ចួនក្នុងវគ្គ(រូបសម្ពស្សក្នុង)

ព្យាង្គទី៤ នៃឃ្លាទី១ ចួននឹង ព្យាង្គទី២ ឬទី៤ នៃឃ្លាទី២។

ព្យាង្គទី៦ នៃឃ្លាទី២ ចួននឹងព្យាង្គទី៤ នៃឃ្លាទី៣ ចួននឹងព្យាង្គទី២ ឬទី៤ នៃឃ្លាទី៤។

(...ចួននឹងព្យាង្គទី២ នៃឃ្លាទី៤ កវីខ្លះពុំបានអនុវត្តចំណាប់ចួននេះទេ)

-ចួនឆ្លងវគ្គ(រូបសម្ពស្សក្រៅ)

ព្យាង្គទី៦ នៃឃ្លាទី៤ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី៦ នៃឃ្លាទី២ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖

| | |
|---|---|
| - ជុចថាអើហោង | បើនឹងចង់ល្បងឥឡូវ |
| នេះហើយសមត្រូវ | នឹងម្ជូរប្រហើរភ្លាអាំង ។ |
| - ត្រីថាអះអើ | ប៉ើងរ៉ើងទេតើម្ដេចខ្លាំង |
| អួតមានកម្លាំង | គិតថាអញខ្លាចណាស់ហោង ។ (វិសេសដូង "ល្បើកជុចនិងត្រី") |

## ៦- បទ ពំនោល (ពំនោល, ពោល = ការពោលរៀបរាប់...)

*** បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បទនេះ ប្រើសម្រាប់រៀបរាប់ពីកំហឹងក្រេវក្រោធ សង្សឹកសន្ធាប់ គំរាមកំហែង មហិទ្ធិរិទ្ធិ ឬអំណាចតេជៈរបស់អ្នកខ្លាំងពូកែ ពាក្យអង្វរករ ភ័យខ្លាចរបស់អ្នកខ្សោយ ឬជម្លោះចំបាំង ដែលមានចលនាក្នុងក្ដាំង និងពោលក្នុងការសម្ដែងរបាំ (ញ៉ាំងនាដករ/នាដការិនី ធ្វើចលនា និងកាយវិការផ្សេងៗតាមបទភ្លេង...) ។

*** គំនូសតាងបទកាព្យ**

①②③④⑤⑥ ①②③④ ①②③④⑤⑥

①②③④⑤⑥ ①②③④ ①②③④⑤⑥ ។

***រង្វាស់កាព្យ(កាព្យមាត្រ)**

-១វគ្គ(ល្បះ)មាន៣ឃ្លា ឃ្លាទី១,ទី៣ មាន៦ព្យាង្គ និងឃ្លាទី២ មាន៤ព្យាង្គ។

***ចំណាប់ចុងចួន(រូបសម្ពស្ស)**

- ចួនក្នុងវគ្គ(រូបសម្ពស្សក្នុង)

ព្យាង្គទី៦ នៃឃ្លាទី១ ចួននឹង ព្យាង្គទី៤ នៃឃ្លាទី២។

ព្យាង្គទី៤ នៃឃ្លាទី២ ចួននឹងព្យាង្គទី២ នៃឃ្លាទី៣ (កវីខ្លះពុំបានអនុវត្តចំណាប់ចួននេះទេ)។

-ចួនឆ្លងវគ្គ(រូបសម្ពស្សក្រៅ)

ព្យាង្គទី៦ នៃឃ្លាទី៣ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី៦ នៃឃ្លាទី១ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖

| | | |
|---|---|---|
| - សាលាជាថ្នាលបណ្ដុះ | កូនខ្មែរស្រីប្រុស | ឲ្យមានវិជ្ជាគ្រប់ប្រាណ ។ |
| - អប់រំនិស្សិតឲ្យបាន | ជាជនចំណាន | រស់នៅក្នុងសង្គមថ្មី ។ |

## ៧- បទភុជង្គលីលា (ភុជង្គៈ នាគ, សត្វនាគ + លីលាៈ ដំណើរ = ដំណើរនាគ, នាគលូន)

* **បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បុរាណប្រើបទនេះក្នុងពេល ធ្វើដំណើរចរលីលា។ រៀបរាប់ពីព្រៃព្រឹក្សា គិរីបព្វតា(ភ្នំ) និងសរសើរពីសម្រស់ធម្មជាតិជាដើម។

* **គំនូសតាងបទកាព្យ**

- ①②③④⑤⑥ ①②③④ ①②③④ ។
- ①②③④⑤⑥ ①②③④ ①②③④ ។

***រង្វាស់កាព្យ(កាព្យមាត្រ)**

-១វគ្គ(ល្បះ)មាន៣ឃ្លា ឃ្លាទី មាន៦ព្យាង្គ និងឃ្លាទី២,ទី៣ មាន៤ព្យាង្គ។

***ចំណាប់ចុងចួន(រូបសម្ពស្ស)**

- ចួនក្នុងវគ្គ(រូបសម្ពស្សក្នុង)
  ព្យាង្គទី៦ នៃឃ្លាទី១ ចួននឹង ព្យាង្គទី៤ នៃឃ្លាទី២។
-ចួនឆ្លងវគ្គ(រូបសម្ពស្សក្រៅ)
  ព្យាង្គទី៤ នៃឃ្លាទី៣ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី៦ នៃឃ្លាទី១ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖

- នេះបទកំណត់ចងជា ភុជង្គលីលា ល្បើករឿងបុរាណ ។
- ថ្លែងពីឥន្ទ្រីសាមាន្យ នៅព្វជ៍ឋាន សួគ៌ាមែនពិត ។
- ជាអង្គសេនាជំនិត ឥសូរទ្រង់ឫទ្ធិ គ្រប់គ្រងដែនដី ។ (សមាគមញ្ញូនពុទ្ធិបពោធនមិត្ត,២០០៣)

## ៨- បទពាក្យ៦ (បទមេ៦)

បទពាក្យ៦ គេពុំសូវប្រទះឃើញប្រើក្នុងសៀវភៅកាព្យនានាទេ។ បទនេះ ប្រទះឃើញប្រើក្នុងរឿងរាមកេរ្តិ៍ (ខ្សែទី៧ដល់៨០)តែករវីដាក់ឈ្មោះផ្សេង ឯក្នុងរឿងរតនាវង្សដាក់ឈ្មោះចំថា បទពាក្យ៦តែម្តង។

* **បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បទនេះអាចប្រើបានគ្រប់បរិយាកាសទាំងអស់។

* **គំនូសតាងបទកាព្យ**

- ①②③④⑤⑥ ①②③④⑤⑥
  ①②③④⑤⑥ ①②③④⑤⑥ ។
- ①②③④⑤⑥ ①②③④⑤⑥
  ①②③④⑤⑥ ①②③④⑤⑥ ។

***រង្វាស់កាព្យ(កាព្យមាត្រ)**

-១វគ្គ(ល្បះ)មាន៤ឃ្លា ឃ្លានីមួយៗ មាន៦ព្យាង្គ។

***ចំណាប់ចុងចួន(រូបសម្ពស្ស)**

- ចួនក្នុងវគ្គ(រូបសម្ពស្សក្នុង)
  ព្យាង្គទី៦ នៃឃ្លាទី១ ចួននឹង ព្យាង្គទី២ ឬទី៤ នៃឃ្លាទី២។
  ព្យាង្គទី៦នៃឃ្លាទី២ ចួននឹងព្យាង្គទី៦នៃឃ្លាទី៣ ចួននឹងព្យាង្គទី២ ឬទី៤ នៃឃ្លាទី៤ ។
  (...ចួននឹងព្យាង្គទី២ ឬទី៤នៃឃ្លាទី៤ បើចួនព្យាង្គណាត្រូវគោរពពីដើមរហូតដល់ចប់)
-ចួនឆ្លងវគ្គ(រូបសម្ពស្សក្រៅ)
  ព្យាង្គទី៦ នៃឃ្លាទី៤ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី៦ នៃឃ្លាទី២ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖ - រៀនសូត្រត្រូវចេះត្រងត្រាប់ សួរសព្វគ្រូប្រាប់ប៉ុន្មាន
សុ.ចិ.បុ.លិ.លំអាន ចំណានចំណេះប្រាកដ ។
- វិន័យប្រពៃពេកពិត ប្រឌិតកែច្នៃអំណត់
សុខភាពមាំមួនហ្មត់ចត់ សន្ទុតជឿជាក់ជោគជ័យ ។

## ៩- បទពាក្យ៧ (បទមេ៧)

ចាប់ពីបទពាក្យ៧ ដល់បទពាក្យ១១ (កើតក្នុងសម័យចតុមុខ) កំណាព្យខ្មែរបានឈានដល់ដំណាក់កាលមួយថ្មីទៀត កវីបានបង្កើតក្បួនតែងកាព្យងាយៗ(ចំណាប់ចួន និងបរិយាកាស)។

* **បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បទនេះអាចប្រើបានគ្រប់បរិយាកាសទាំងអស់។
* **គំនូសតាងបទកាព្យ**

- ①②③④⑤⑥⑦ ①②③④⑤⑥⑦
①②③④⑤⑥⑦ ①②③④⑤⑥⑦ ។
- ①②③④⑤⑥⑦ ①②③④⑤⑥⑦
①②③④⑤⑥⑦ ①②③④⑤⑥⑦ ។

***រង្វាស់កាព្យ(កាព្យមាត្រ)**

-១វគ្គ(ល្បះ)មាន៤ឃ្លា ឃ្លានីមួយៗ មាន៧ព្យាង្គ។

***ចំណាប់ចុងចួន(រូបសម្ពស្ស)**

- ចួនក្នុងវគ្គ(រូបសម្ពស្សក្នុង)

ព្យាង្គទី៧ នៃឃ្លាទី១ ចួននឹង ព្យាង្គទី២ ឬទី៤ នៃឃ្លាទី២។
ព្យាង្គទី៧ នៃឃ្លាទី២ ចួននឹងព្យាង្គទី៧នៃឃ្លាទី៣ ចួននឹងព្យាង្គទី២ ឬទី៤ នៃឃ្លាទី៤ ។
(...ចួននឹងព្យាង្គទី២ ឬទី៤នៃឃ្លាទី៤ បើចួនព្យាង្គណាត្រូវគោរពពីដើមរហូតដល់ចប់)

-ចួនឆ្លងវគ្គ(រូបសម្ពស្សក្រៅ)

ព្យាង្គទី៧ នៃឃ្លាទី៤ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី៧ នៃឃ្លាទី២ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖ - ហៃសាធុជនទាំងអស់គ្នា ចំណេះវិជ្ជាទាំងសម្វាយ
មានគុណវិសេសធំទូលាយ គួរយើងវែចស្ពាយកុំខ្លាចធ្ងន់ ។
- មិនលំបាកទុកស្រណុកលាក់ ជាជាងមាសប្រាក់សព្វទ្រព្យធន
មិនខ្លាចចោរលួច ឬចោរប្លន់ ទៅគ្រប់តំបន់គ្រាន់ជាស្បៀង ។
- ឥតកណ្ដៀរកោរកណ្ដុរកាត់ ចាយណាស់មិនបាត់មិនមានល្អៀង
ចាយច្រើនកើនច្រើនចម្រើនទៀង ពីបច្ចុប្បន្នរៀងទៅបរលោក ។(ក្រសួងអប់រំជាតិ, ទសវត្ស៦០)

## ១០- បទពាក្យ៨ (បទមេ៨)

* **បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បទនេះអាចប្រើបានគ្រប់បរិយាកាសទាំងអស់។
* **គំនូសតាងបទកាព្យ**

- ①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧
①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧ ។
- ①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧
①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧ ។

*វង្វាស់កាព្យ(កាព្យមាត្រ)

-១វគ្គ(ល្បះ)មាន៤ឃ្លា ឃ្លានីមួយៗ មាន៨ព្យាង្គ។

*ចំណាប់ចុងចួន(រូបសម្ពស្ស)

- ចួនក្នុងវគ្គ(រូបសម្ពស្សក្នុង)

ព្យាង្គទី៨ នៃឃ្លាទី១ ចួននឹង ព្យាង្គទី៣ ឬទី៥ នៃឃ្លាទី២។

ព្យាង្គទី៨ នៃឃ្លាទី២ ចួននឹងព្យាង្គទី៨នៃឃ្លាទី៣ ចួននឹងព្យាង្គទី៤ ឬទី៥ នៃឃ្លាទី៤ ។

(...ចួននឹងព្យាង្គទី៣ ឬទី៥នៃឃ្លាទី២ និងឃ្លាទី៤ មានលក្ខណៈមិនដាច់ខាតចំពោះបែបទី៣ )

-ចួនឆ្លងវគ្គ(រូបសម្ពស្សក្រៅ)

ព្យាង្គទី៨ នៃឃ្លាទី៤ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី៨ នៃឃ្លាទី២ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖

- អនិច្ចាតោថ្មលោកក**សាង** មើលថា**ថាង**យ៉ាងរស់ស្មុះប្រែប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់ខ្ចាត់**ខ្ចាយ** ស្ដាយអើយ**ស្ដាយ**មិនគួរមកពិ**ការ** ។
- មានអ្នកព្រៃចង្រៃឥតគំ**និត** មកសំលៀងកាំ**បិត**គ្រឿងប្រ**ហារ**
ឲ្យខូងខូចខាតសាច់ បង់អ**សារ** មិនស្ដាយការ**ស្នា**ដៃបូរាណ**សោះ** ។
- ឱ!តោអើយតោឈរមិនមើល**មៀង** មកឲ្យគេសំ**លៀង**ខ្នងតោចុះ
ម្ដេចមិនខឹងខាំវាសំលៀង**នោះ** ឲ្យវា**លុះ**ក្ដីមរណ៍យក៏វាទៅ ។(សុត្តន្តប្រីជាឥន្ទ)

# ១១- បទពាក្យ៩ (បទមេ៩)

<u>**កំណត់សម្គាល់៖**</u> បទពាក្យ៩នេះ ក្នុងសំណេរជួនកាល ស្មេរ(ឬកវី)សរសេរជេកឃ្លាបី(៣)ៗព្យាង្គ ក្នុងឃ្លានីមួយៗ(មិនមែនជាបទពាក្យ៣ទេ)រហូតដល់ចប់។

* **បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បទនេះអាចប្រើបានគ្រប់បរិយាកាសទាំងអស់។

* **គំនូសតាងបទកាព្យ**

- ①②③④⑤⑥⑦⑧⑨ ①②③④⑤⑥⑦⑧⑨
①②③④⑤⑥⑦⑧⑨ ①②③④⑤⑥⑦⑧⑨ ។
- ①②③④⑤⑥⑦⑧⑨ ①②③④⑤⑥⑦⑧⑨
①②③④⑤⑥⑦⑧⑨ ①②③④⑤⑥⑦⑧⑨ ។

*វង្វាស់កាព្យ(កាព្យមាត្រ)

-១វគ្គ(ល្បះ)មាន៤ឃ្លា ឃ្លានីមួយៗ មាន៩ព្យាង្គ។

*ចំណាប់ចុងចួន(រូបសម្ពស្ស)

- ចួនក្នុងវគ្គ(រូបសម្ពស្សក្នុង)

ព្យាង្គទី៩ នៃឃ្លាទី១ ចួននឹង ព្យាង្គទី៣ ឬទី៦ នៃឃ្លាទី២។

ព្យាង្គទី៩ នៃឃ្លាទី២ ចួននឹងព្យាង្គទី៩នៃឃ្លាទី៣ ចួននឹងព្យាង្គទី៣ ឬទី៦ នៃឃ្លាទី៤ ។

(ដើម្បីកាន់តែមានសម្ពស្ស និងពីរោះ កវីបានបន្ថែមចំណាប់ចុងចួនក្នុងឃ្លានីមួយៗទៀត គឺរវាងព្យាង្គទី៣និងទី៤,ព្យាង្គទី៦ និង៧ ហៅថា*បទជាប់ទង* ដែលជាបទទ្វេមាត្រ...)

-ចួនឆ្លងវគ្គ(រូបសម្ពស្សក្រៅ)

ព្យាង្គទី៩ នៃឃ្លាទី៤ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី៩ នៃឃ្លាទី២ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖ - ស្មោចញៀនរៀនដុះផុងក្នុងវារី នៅសល់ពីទីទឹកស្មានបានពីរឆ្នាប់
ខ្យល់បក់បោកខោកឥតស្រាកងាករញ្ជាប់ នៅមិនងាប់ជាប់រហូតលូតឡើងបាន ។
- ជាតិបណ្ឌិតពិតពីរោះឈ្មោះឥតអាក់ មានឧបសគ្គស្ទាក់រាំងទាំងប៉ុន្មាន
ប្រឹងរុករានឈានឥតខ្សោយដោយក្លាហាន ត្រាតែប្រាណបានរួចទុក្ខសុខដូចស្មៅ ។
(ឥន្ទមុនី សេក នាង)

## ១២- បទពាក្យ១០ (បទមេ១០)

<u>កំណត់សម្គាល់៖</u> បទពាក្យ១០នេះ ក្នុងសំណេរជួនកាល ស្មេរ(ឬកវី)សរសេរដកឃ្លាប្រាំៗព្យាង្គ ក្នុងឃ្លានីមួយៗ(មិនមែនជាបទពាក្យ៥ទេ)រហូតដល់ចប់។

* **បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បទនេះអាចប្រើបានគ្រប់បរិយាកាសទាំងអស់។

* **គំនូសតាងបទកាព្យ**

- ①②③④⑤⑥⑦⑧⑨⑩ ①②③④⑤⑥⑦⑧⑨⑩
①②③④⑤⑥⑦⑧⑨⑩ ①②③④⑤⑥⑦⑧⑨⑩ ។
-①②③④⑤⑥⑦⑧⑨⑩ ①②③④⑤⑥⑦⑧⑨⑩
①②③④⑤⑥⑦⑧⑨⑩ ①②③④⑤⑥⑦⑧⑨⑩ ។

***រង្វាស់កាព្យ(កាព្យមាត្រ)**

-១វគ្គ(ល្បះ)មាន៤ឃ្លា ឃ្លានីមួយៗ មាន១០ព្យាង្គ។

***ចំណាប់ចុងចួន(រូបសម្ទស្ស)**

- ចួនក្នុងវគ្គ(រូបសម្ទស្សក្នុង)
ព្យាង្គទី១០ នៃឃ្លាទី១ ចួននឹង ព្យាង្គទី៥ នៃឃ្លាទី២។
ព្យាង្គទី១០ នៃឃ្លាទី២ ចួននឹងព្យាង្គទី១០នៃឃ្លាទី៣ ចួននឹងព្យាង្គទី៥ នៃឃ្លាទី៤ ។

-ចួនឆ្លងវគ្គ(រូបសម្ទស្សក្រៅ)
ព្យាង្គទី១០ នៃឃ្លាទី៤ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី១០ នៃឃ្លាទី២ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖

- ពលរដ្ឋគ្រប់ប្រាណបានយល់ដឹងច្បាប់គ្រឹះជាតិ គោរពឥតបីឃ្លាតរដ្ឋធម្មនុញ្ញកៅបី
ទាំងរាស្ត្រមន្ត្រីយល់កិច្ចនិងសិទ្ធិសេរី ជាតិខ្មែរបានល្បាញល្បីកិត្តិសព្ទល្បីសុះសាយ ។
- លើកស្ទួយសាមគ្គីមិត្តម្នាជួយគ្នាគ្រាក្រ សប្បុរសស្មោះសផងនគរសប្បាយ
មង្គលទីបួនផ្លូវចិត្តស្ងប់និងសុខកាយ លែងកើតកលខ្វល់ខ្វាយបាយទឹកព្រឹកល្ងាចមាន ។

## ១៣- បទពាក្យ១១(បទមេ១១)

<u>កំណត់សម្គាល់៖</u> បទពាក្យ១១នេះ ក្នុងសំណេរជួនកាល ស្មេរ(ឬកវី)សរសេរដកឃ្លាប្រាំមួយព្យាង្គ និងប្រាំព្យាង្គក្នុងឃ្លានីមួយៗ (មិនមែនជាបទកាព្យអ្វីផ្សេងនោះទេ)រហូតដល់ចប់។

* **បរិយាកាស(ប្រើប្រាស់តាមកាលៈទេសៈ)** បទនេះអាចប្រើបានគ្រប់បរិយាកាសទាំងអស់។

* គំនូសតាងបទកាព្យ

- ①②③④⑤⑥⑦⑧⑨⑩○ ①②③④⑤⑥⑦⑧⑨⑩○
①②③④⑤⑥⑦⑧⑨⑩○ ①②③④⑤⑥⑦⑧⑨⑩○ ។
- ①②③④⑤⑥⑦⑧⑨⑩○ ①②③④⑤⑥⑦⑧⑨⑩○
①②③④⑤⑥⑦⑧⑨⑩○ ①②③④⑤⑥⑦⑧⑨⑩○ ។

*រង្វាស់កាព្យ(កាព្យមាត្រ)

-១វគ្គ(ល្បះ)មាន៤ឃ្លា ឃ្លានីមួយៗ មាន១១ព្យាង្គ។

*ចំណាប់ចុងចួន(រូបសម្ផស្ស)

- ចួនក្នុងវគ្គ(រូបសម្ផស្សក្នុង)

ព្យាង្គទី១១ នៃឃ្លាទី១ ចួននឹង ព្យាង្គទី៣ នៃឃ្លាទី២។

ព្យាង្គទី១១ នៃឃ្លាទី២ ចួននឹងព្យាង្គទី១១នៃឃ្លាទី៣ ចួននឹងព្យាង្គទី៣ នៃឃ្លាទី៤ ។

(ដើម្បីកាន់តែមានសម្ផស្ស និងពីរោះ កវីបានបន្ថែមចំណាប់ចុងចួនក្នុងឃ្លានីមួយៗ)

-ចួនឆ្លងវគ្គ(រូបសម្ផស្សក្រៅ)

ព្យាង្គទី១១ នៃឃ្លាទី៤ ក្នុងវគ្គទី១(វគ្គមុន) ចួននឹង ព្យាង្គទី១១ នៃឃ្លាទី២ ក្នុងវគ្គទី២(វគ្គបន្ទាប់)។

ឧទាហរណ៍៖

- តាមផ្លូវឃើញជាក់ភ្ញាក់ខ្លួនដឹងប្រឹងពិនិត្យ**គិត** កើតគំ**និត**សង្វេគណាស់ច្បាស់ថាក្ស័យមរ**ណា**
បើកបរភ្លេចខ្លួនកាន់ក្បួនច្បាប់ចាប់យកសុ**រា** អនិច្ចាជីវិតពិតជាស្លាប់គ្មានខ្លឹម**សារ** ។
- ឱ!លោកអើយឃើញជាក់ហើយផ្តល់គតិមកចុះ កើតជា**ប្រុស**ផឹកស្រាជក់បារីចូលបន**បារ**
ទើបសមជាក់ជាប្រុសមានដើមទ្រូងប្រាំហត្ថា ពង្ស**វង្ស**មានកិត្តិយសឈ្មោះពីរោះឬ?!...

***ដូចនេះ កំណាព្យបទមូលដ្ឋាន មានទាំងអស់***១៣បទ***គឺ បទពាក្យ៤ បទបថ្យាវត្ត បទកាកគតិ បទពំនោល បទព្រហ្មគីតិ បទបន្ទោលកាក បទភុជង្គលីលា បទពាក្យ៦ បទពាក្យ៧ បទពាក្យ៨ បទពាក្យ៩ បទពាក្យ១០ និងបទពាក្យ១១ ។

បទមូលដ្ឋានទាំងនេះ គឺជាក្បួនគោលសម្រាប់យកទៅបង្កើតបទថ្មីៗទៀត ដែលមានឈ្មោះថា **បទទ្វេមាត្រ** ៕

✂--------------------